ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

លេខ : ៦៩..........អ/សដ.ភ

ភ្នំពេញ, ថ្ងៃទី២៤ ខែ មករា ឆ្នាំ ២០០៦

អគ្គនាយកសុរិយោដី និង ភូមិសាស្ត្រ

**ជំរាបជូន**

លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានីភ្នំពេញ

**កម្មវត្ថុ :** អំពីបញ្ហាទាក់ទងនឹងការផ្ទេរដី-ផ្ទះ ក្នុងតំបន់ដែលបានធ្វើការវិនិច្ឆ័យរួចហើយ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបលោកប្រធានថា : កន្លងមក ក្រុមការងារអនុវត្តគំរោង LMAP ក្រុងភ្នំពេញ តែងជួបបញ្ហារាំងស្ទះក្នុងការផ្ទេរសិទ្ធិដី-ផ្ទះ ។ ករណីបណ្តាលមកពីមិនទាន់មានដំណោះស្រាយ និង គោលការណ៍អំពីការចុះបញ្ជីដី-ផ្ទះ ដែលម្ចាស់ក្បាលដីមិនទាន់បានផ្ទេរសិទ្ធិពីម្ចាស់មុនតាមផ្លូវការ ហើយក្រុមការងារអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ បានកត់ចូលក្នុងឯកសារនូវឈ្មោះម្ចាស់ថ្មី ប៉ុន្តែ មន្ទីរមិនទាន់បានចែកវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុជូនម្ចាស់ដី-ផ្ទះតែប៉ុណ្ណោះ ។

ពិនិត្យឯកសារសុរិយោដីកសាងឡើងដោយក្រុមការងារអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ មានតែទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីទេ ដែលបានបង្ហាញច្បាស់លាស់អំពីប្រភពនៃការកាន់កាប់ តាមរយៈការទិញ ឬ ធ្វើអំណោយ ។

ដូចនេះ មានតែទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ( ច្បាប់ដើម) ដែលអាចយកជាមូលដ្ឋានឯកសារ សំរាប់ការប្រថាប់ត្រាផ្ទេរ/ជំនួសលិខិតលក់ផ្តាច់ ឬ អំណោយបាន ។

ស្នើលោកប្រធានមន្ទីរភ្ជាប់ឯកសារនេះ ជូនទៅអង្គភាពពន្ធ ដើម្បីចុះពិនិត្យបន្ថែមលើតម្លៃគិតពន្ធ រួចប្រថាប់ត្រានៅខាងស្តាំដៃនៃចំណុចគ. **សិទ្ធិលើអចលនវត្ថុ** ឬ នៅបន្ទាត់ខាងក្រោមចំពាក្យថា "ទិញ" តែម្តង ។

អាស្រ័យហេតុនេះ សូមលោកប្រធានចាត់ការអនុវត្តតាមខ្លឹមសារខាងលើនេះ ឱ្យបានសំរេច និងទទួលបានលទ្ធផលល្អប្រសើរ ។

អគ្គនាយក

លឹម វ៉ាន់

ចម្លងជូន :

- ក្រសួង ដ.ន.ស
- គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត-ក្រុង អនុវត្តគំរោង LMAP
- ឯកសារ